ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១២៩/១៣-គួប៉ល អាប៉ារ៉ែល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន គួប៉ល អាប៉ារ៉ែល លីមីធីត**

អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៨ ៩៩ ១៨ ២៨៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក សួង ភន មន្ត្រីទំនាក់ទំនង

២- លោក គីម សំអាង ប្រធានធនធានមនុស្ស

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សហព័ន្ធសហជីពកម្មករនិយោជិត**

- **សហជីពកម្មករនិយោជិតរោងចក្រ** GLOBAL

អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ២១០ ៣១៧ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

| | |
|---|---|
| ១- លោក សន ប្រាក់ | អគ្គលេខាធិការសហព័ន្ធសហជីពកម្មករនិយោជិត |
| ២- លោក លឹម តារា | មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត |
| ៣- លោក ផា តូរី | មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត |
| ៤- លោក ប៉ែន ចាន់រិទ្ធិ | មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ខែគោលចំនួន ១៤ ដុល្លារ ក្នុងមួយខែ បន្ថែមពីប្រាក់ឈ្នួលគោលរបស់កម្មករម្នាក់ៗ ដែលធ្លាប់បានទទួលពីមុនមក។ ដោយឡែកភាគីក្រុមហ៊ុនបានអនុវត្តនូវការផ្តល់ប្រាក់ឈ្នួលគោលមិនឱ្យទាបជាងច្បាប់ទេ។ សូមជម្រាបថា បច្ចុប្បន្នក្រុមហ៊ុនបានផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន ៨៥ ដុល្លារ ក្នុងមួយខែ បានប្រមាណ ៨០% រួចហើយ។

២- កម្មករនិយោជិតដែលធ្វើការត្រឹម ៨ ម៉ោង ក្នុងមួយថ្ងៃ សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ជូនគាត់ផង។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុននឹងអនុវត្តតាមគោលការណ៍ចាស់ ព្រោះក្រុមហ៊ុនបានកំណត់បើកម្មករណាធ្វើការដល់ ១០ ម៉ោង ហើយគ្រប់ចំនួនកំណត់ទើបមានប្រាក់រង្វាន់លើកទឹកចិត្តនោះ។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់អាហារថ្ងៃត្រង់មួយពេលជារៀងរាល់ថ្ងៃ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ឱ្យឡើយ។

៤- កម្មករនិយោជិតនៅតែស្នើសុំឱ្យក្រុមហ៊ុនផ្តល់ថ្លៃធ្វើដំណើរចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីក្រុមហុនបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ឱ្យឡើយ។

៥- កម្មករនិយោជិតនៅតែទាមទារកុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់នៅពេលណាកម្មករនិយោជិតធ្វើកូដកម្ម។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនផ្តល់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យកម្មករនិយោជិតទាំងឡាយណាដែលធ្វើកូដកម្មនោះទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួមដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៧៤២ កប/អក/វក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារ បានទទួលលិខិតជូនដំណឹង ធ្វើកូដកម្មរបស់កម្មករនិយោជិត ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងធ្វើកូដកម្មរបស់កម្មករនិយោជិតនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៥ ចំណុច លើការទាមទារចំនួន ១០ ចំណុច។ ចំណុចមិនសះជាចំនួន ០៥ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៧៤២ កប/អក/វក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ហើយលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៥ ចំណុចនេះ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល។ ប៉ុន្តែ ភាគីកម្មករនិយោជិត (សហជីពកម្មករនិយោជិត ប្រចាំក្រុមហ៊ុន) មិនបានមកចូលរួមសវនាការទេ គឺមានតែ លោក សន ប្រាក់ ជាអគ្គលេខាសហព័ន្ធសហជីពកម្មករនិយោជិត ព្រមទាំងលោក លឹម តារា, លោក ជា តូរី និងលោក ប៉ែន ចាន់រិទ្ធិ ជាមន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិតដែលបានចូលរួមសវនាការ ដោយបានប្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ប្រធាន និងលេខាធិការសហជីពមូលដ្ឋាន បានលាឈប់ពីការងារហើយ គឺនៅសល់តែ អ្នកស្រី សួន វណ្ណា ជាអនុប្រធានសហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន ក្លូប័ល អាប៉ារែល លីមីធីត ទេ។ លោក សន ប្រាក់ បានបញ្ជាក់បន្ថែមថា មុនពេលគាត់មកចូលរួមសវនាការ គាត់បានទាក់ទងតាមរយៈទូរស័ព្ទទៅអ្នកស្រី សួន វណ្ណា ហើយអ្នកស្រីបានប្រាប់គាត់ថា មានជំងឺមិនអាចមកចូលរួមសវនាការបានទេ ហើយក៏មិនបានផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរ ជូនសហព័ន្ធសហជីពកម្មករនិយោជិតឱ្យតំណាងគាត់នៅក្នុងការដោះស្រាយវិវាទនៅក្នុងសំណុំរឿងនោះទេ។ ចំណែកឯ ភាគីនិយោជកបានចូលរួមសវនាការ តាមការអញ្ជើញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោម ៖

**គស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់លោក ជីវ សេងគ័រ ជានាយកក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល លីមីធីត ផ្ទេរសិទ្ធិជូនលោក គឹម សំអាង និងលោក សួង ភន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មលេខ ៣៩៨៤ ពណ.ចបព ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ របស់ក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល លីមីធីត។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល លីមីធីត លេខ ០២៦ កប/អក/អធក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ២៣០ ក.ប/អក/វក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ របស់នាយកដ្ឋានវិវាទការងារជំរាបមក អ្នកស្រីប្រធានសហជីពកម្មករនិយោជិតរោងចក្រ GLOBAL ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ក្លូប័ល លេខ ៧៤២ កប/អក/វក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ក្លូប័ល ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៦២៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៦២៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣។

៣- កិច្ចព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទវិវាទអំពីសិទ្ធិ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល លីមីធីត ដែលជាដើមបណ្តឹងមិនបានមកចូលរួមសវនាការទេ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និង ភាគីកម្មករនិយោជិត មកសវនាការ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល។ ប៉ុន្តែ ភាគីកម្មករនិយោជិត (សហជីពកម្មករនិយោជិត ប្រចាំក្រុមហ៊ុន) មិនបានមកចូលរួមសវនាការទេ គឺមានតែតំណាងសហព័ន្ធដែលបានចូលរួមសវនាការ។ នៅក្នុងសវនាការ លោក សន ប្រាក់ ដែលជាអគ្គលេខាធិការសហព័ន្ធសហជីព កម្មករនិយោជិត បានប្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ប្រធានសហជីព និង លេខាធិការសហជីព បានលាឈប់ពីការងារហើយ គឺនៅសល់តែ អ្នកស្រី សួន វណ្ណា ជាអនុប្រធានសហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន ក្លូប័ល អាប៉ារែល លីមីធីត ទេ។ លោក សន ប្រាក់ បានបញ្ជាក់បន្ថែមថា មុនពេលគាត់មកចូលរួមសវនាការ គាត់បានទាក់ទងតាមរយៈទូរស័ព្ទទៅអ្នកស្រី សួន វណ្ណា ហើយអ្នកស្រីបានប្រាប់គាត់វិញថា គាត់មានជំងឺមិនអាចមកចូលរួមសវនាការបានទេ ហើយអ្នកស្រី សួន វណ្ណា និងកម្មករនិយោជិតដទៃទៀត នៃក្រុមហ៊ុន ក្លូប័ល អាប៉ារែល លីមីធីត មិនបានធ្វើលិខិតផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរ ជូនសហព័ន្ធសហជីពកម្មករនិយោជិតធ្វើជាតំណាងពួកគាត់ នៅក្នុងការដោះស្រាយវិវាទនៅក្នុងសំណុំរឿងនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថាតើ នឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានដើមបណ្តឹង?

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួនទៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"* ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វ៉េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍ និងលេខ ១៣១/១២-ម៉ាស្ទ័រ & ប្រេង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល *លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញ ត្រឹមត្រូវ, លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួនទៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន"* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី១ ៖ *ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ***

មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទំនាក់ទំនងទៅកាន់ភាគីកម្មករនិយោជិត ដោយជូនដំណឹងពីសវនាការនាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ តាមរយៈលិខិតអញ្ជើញលេខ ៦២៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ដោយបានទទួល ហើយបានចុះហត្ថលេខាទទួលពីលោក ប៉ែន ចាន់រទ្ធិ ជាមន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០១៣ វេលាម៉ោង ៩ និង ០៨ នាទី ព្រឹក។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី២ ៖ *ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល***

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា “*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*” នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាលដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ អនុប្រធានសហជីពកម្មករនិយោជិត ប្រចាំក្រុមហ៊ុន ក្លប័ល អាប៉ារែល លីមីធីត ដែលជាដើមបណ្តឹងមិនបានអញ្ជើញមកចូលរួមសវនាការអាជ្ញាកណ្តាលទេ។ ពោល គឺគ្រាន់តែបានប្រាប់ លោក សន ប្រាក់ ដែលជាអគ្គលេខាធិការសហព័ន្ធសហជីពកម្មករនិយោជិតថា គាត់មានជំងឺ និងមិនអាចចូលរួមសវនាការទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានបង្ហាញខ្លួននៅក្នុងសវនាការទេ។ ហេតុនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី៣ ៖ *ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន***

នៅក្នុងករណីនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល។ ប៉ុន្តែ រហូតដល់ពេលក្រុមប្រឹក្សាអាជ្ញាកណ្តាលបើកសវនាការ ទើបលោក សន ប្រាក់ អគ្គលេខាធិការសហព័ន្ធសហជីពកម្មករនិយោជិតប្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលថា អ្នកស្រី សួន វណ្ណា ជាអនុប្រធានសហជីពមូលដ្ឋាន មិនអាចចូលរួមសវនាការពីព្រោះថាគាត់មានជំងឺ។ ប៉ុន្តែ លោក សន ប្រាក់ មិនបានបញ្ជាក់ថា អ្នកស្រី សួន វណ្ណា មានជំងឺអ្វីនោះទេ គឺគ្រាន់តែបញ្ជាក់ថា ឈឺតែប៉ុណ្ណោះ។ ចំណែកឯ ថ្នាក់ដឹកនាំសហជីពដទៃទៀត (ប្រធានសហជីព ឬលេខាធិការសហជីព)

ក៏មិនមកចូលរួមសវនាការដែរ ពីព្រោះពួកគាត់បានលាឈប់ពីការងារហើយ ហើយក៏មានកម្មករនិយោជិត ណាម្នាក់បានមកចូលរួមសវនាការដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាបន្ត ដូចខាងក្រោម ៖

ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ភាគី វិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬអ្នកតំណាង ដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

យោងតាមប្រការ១៩ នៃប្រកាសលេខ ៩៩/០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យថា *"ទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ"* មានន័យថា ភាគីវិវាទអាចឱ្យបុគ្គលផ្សេងតំណាងឱ្យខ្លួនក្នុងការដោះស្រាយវិវាទការងារនៅចំពោះមុខក្រុមអាជ្ញាកណ្តាលបាន លុះត្រាតែបុគ្គលនោះទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដើម្បីមកធ្វើជាតំណាងរបស់ភាគីវិវាទ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៦១/០៩-សិប្បកម្ម ព្រែកព្រៃង, លេខ ៤៣/១០-ម៉ីង ជៀន និងលេខ ១៤៤/១២-អ៊ី ហ្គាមេន)*។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត (ភាគីដើមបណ្តឹង) មិនបានបង្ហាញខ្លួន ហើយអគ្គលេខាធិការ និងមន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិតដទៃទៀត ក៏មិនទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ឬ លិខិតផ្ទេរសិទ្ធិត្រឹមត្រូវ ដើម្បីមកធ្វើជាតំណាងដោះស្រាយវិវាទនៅក្នុងសំណុំរឿងនេះ ពីអនុប្រធានសហជីព ក៏ដូចជាពីកម្មករនិយោជិតដទៃទៀត នៅក្នុងក្រុមហ៊ុន ដែលជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សំគាល់ឃើញថា មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិតបានទទួលលិខិតអញ្ជើញពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ៩ និង ០៨ នាទីព្រឹក ដែលបានបញ្ជាក់យ៉ាងច្បាស់ថា សវនាការនឹងប្រព្រឹត្តទៅនាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អ្នកស្រី សួន វណ្ណា ឬ ដើមបណ្តឹងដទៃទៀត មានរយៈពេល ៣ ថ្ងៃ ក្នុងការធ្វើការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ឬ លិខិតផ្ទេរសិទ្ធិត្រឹមត្រូវ ជូនសហព័ន្ធសហជីពកម្មករនិយោជិត ដើម្បីក្លាយជាតំណាងរបស់ខ្លួន ក្នុងការដោះស្រាយវិវាទចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលពាក្យបណ្តឹងរបស់ខ្លួន។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ **១២៩/១៣-ក្លូប័ល អាប៉ារែល លីមីធីត** នេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ **១២៩/១៣-ក្លូប័ល អាប៉ារែល លីមីធីត**

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុរិទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL